# តើសំរាប់អ្នកណា?

សូមទំនាក់ទំនងមកសាខា សេ អឹម កា ទាំង ១៩
ណាមួយរឺទូរស័ព្ទមកលេខ ០៧៧ ៤០០ ៣៣៥

# កម្ចីសិក្សា STUDENT LOAN

កម្ចីសិក្សារបស់ សេ អឹម កា គឺ អាស្រ័យលើ គុណតំលៃ និងលទ្ធផលនៃការសិក្សាជាចំបង។ នេះមានន័យថា អ្វីដែលអ្នកត្រូវការ គឺការខិតខំសិក្សា ទោះបីជាការរៀនបណ្តុះបណ្តាលវគ្គខ្លី ថ្នាក់បរិញ្ញាប័ត្រ រឺ ថ្នាក់អនុបណ្ឌិត។

និស្សិតគ្រប់រូបអាចដាក់ពាក្យស្នើកម្ចីសិក្សានេះ។ ហេតុដូច្នេះ ប្រញាប់មកដាក់ពាក្យឥឡូវកុំឲ្យឱកាសល្អនេះកន្លងផុតទៅ។



## សាខាភ្នំពេញ

| | |
|---|---|
| 1. សេអឹមកា សាខាកណ្ដាល | Tel: 023 221 971 / 077 400 331 |
| 2. សេអឹមកា សាខាបឹងកេងកង | Tel: 023 727 624 / 077 400 327 |
| 3. សេអឹមកា សាខាច្បារអំពៅ | Tel: 023 720 446 / 077 400 316 |
| 4. សេអឹមកា សាខាទួលទំពូង | Tel: 023 220 223 / 077 400 326 |
| 5. សេអឹមកា សាខាព្រះអង្គឌួង | Tel: 023 724 226 / 077 400 315 |
| 6. សេអឹមកា សាខាពោធិ៍ចិនតុង | Tel: 023 866 395 / 077 400 318 |
| 7. សេអឹមកា សាខាអូឬស្សី | Tel: 023 724 336 / 077 400 317 |
| 8. សេអឹមកា សាខាស្ទឹងមានជ័យ | Tel: 023 969 015 / 077 400 314 |
| | Tel: 023 969 025 / 077 400 319 |
| 9. សេអឹមកា សាខាស្តាតអូឡាំពិច | Tel: 023 216 268 / 023 220 243 |
| | Tel: 077 400 313 / 077 400 312 |

## សាខាខេត្ត

| | |
|---|---|
| 10. សេអឹមកា សាខាកំពង់ឆ្នាំង | Tel: 026 770 107 / 077 400 325 |
| 11. សេអឹមកា សាខាកំពង់ស្ពឺ | Tel: 025 987 186 / 077 400 322 |
| 12. សេអឹមកា សាខាសៀមរាប១ | Tel: 063 764 207 / 077 400 324 |
| 13. សេអឹមកា សាខាសៀមរាប២ | Tel: 063 765 603 / 077 400 328 |
| 14. សេអឹមកា សាខាតាកែវ | Tel: 032 931 631 / 077 400 321 |
| 15. សេអឹមកា សាខាល្វាឯម | Tel: 077 400 320 |
| 16. សេអឹមកា សាខាអូរ៉ាំងឪ | Tel: 042 633 633 8 / 077 400 323 |
| 17. សេអឹមកា សាខាបាត់ដំបង | Tel: 053 953 553 / 077 400 330 |
| 18. សេអឹមកា សាខាកែប | Tel: 036 210 300 / 099 444 003 |
| 19. សេអឹមកា សាខាក្រុងព្រះសីហនុ | Tel: 034 210 620 / 099 444 031 |



ក្រេឌីមុយទុយអែលកម្ពុជា (សេ អឹម កា) ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជា នៅឆ្នាំ ២០០៤ ដោយសង្គហធនាគារធំទី ២ របស់ប្រទេសបារាំងឈ្មោះ ក្រេឌីមុយទុយអែល តាមរយៈ សេ អ៊ី សេ អឹម ។ សេ អឹម កា គឺជាសង្គហធនាគារដែលជាកម្មសិទ្ធិរបស់សមាជិក ដែលបំរើផលប្រយោជន៍រួម។ គោលបំណងរបស់ សេ អឹម កា គឺដើម្បីផ្ដល់ឲ្យអ្នករាល់គ្នា ពិសេសប្រជាជនដែលពុំធ្លាប់ ឬ ពុំអាចប្រើប្រាស់សេវាកម្មធនាគារកន្លងមក នូវឱកាសប្រើប្រាស់សេវាកម្មសន្សំ កម្ចី និង សេវាកម្មធនាគារផ្សេងៗទៀត។

តាមរយៈការសន្សំនៅ សេ អឹម កា អ្នកនឹងទទួលបានអត្ថប្រយោជន៍ តាមរយៈការបង្កើនប្រាក់ចំណូលរបស់អ្នក និង ចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជាផងដែរ។


ការិយាល័យកណ្ដាល
ក្រេឌីមុយទុយអែល កម្ពុជា (CMK)
ផ្ទះលេខ ៨១, ផ្លូវលេខ ១៦៣, ប្រអប់សំបុត្រលេខ ១១០២,ភ្នំពេញ,កម្ពុជា
ទូរស័ព្ទលេខ ០២៣ ២២១ ៩៧១
Email: info@cmk.com.kh – Website: www.cmk.com.kh


April 2017

ទទួលបាននូវអារម្មណ៍ប្លែក!
ហើយអ្នកនឹងមិនមើលមក
ធនាគារក្នុងន័យដដែល

គាំទ្រដោយ

គំរោងរបស់

# ហេតុអ្វីជ្រើសរើសកម្ចីសំរាប់សិក្សា?

សេ អឹម កា ផ្តល់នូវលទ្ធភាពដើម្បីបំពេញគោលដៅរបស់អ្នក និង បង្កើតអាជីពដោយខ្លួនអ្នកផ្ទាល់។ សេ អឹម កា អាចអោយនូវអ្វីដែលអ្នកត្រូវការ សំរាប់ចំណាយលើថ្លៃសិក្សា ។

នេះជាឱកាសមួយសំរាប់អ្នកដើម្បីពង្រឹងស្ថានភាពអាជីពរបស់អ្នក ក៏ដូចជាក៏រិតជីវភាពរបស់អ្នកផងដែរ។

អនាគតគឺជារបស់អ្នក
អ្នកនឹងរៀបចំដោយរបៀបណា
គឺស្ថិតលើខ្លួនអ្នកម្នាក់គត់ !




# តើដំណើរការដោយរបៀបណា?

→ កម្ចីមានភាពបត់បែន ជាមួយ រយៈពេលសងត្រលប់ដល់ទៅ ៧ឆ្នាំ ។

→ អ្នកអាចសងត្រលប់អោយ សេ អឹម កា វិញក្រោយបញ្ចប់ការសិក្សារបស់អ្នកក៏បាន ។

→ សេ អឹម កា មិនផ្តោតទៅលើវត្ថុធានាទេ ប៉ុន្តែ អាស្រ័យលើលទ្ធផលនិង គុណតំលៃ នៃការសិក្សារបស់អ្នក។

→ សេ អឹម កា ផ្តល់នូវអត្រាការប្រាក់ទាប ពិសេសត្រឹមតែ ១%ក្នុង១ខែតែប៉ុណ្ណោះ ។

→ សេ អឹម កា ផ្តល់ជំរើស ៣យ៉ាង ក្នុងការសងត្រលប់ដល់អ្នក

- ★ គ្មានការបង់រំលស់អ្វីទាំងអស់ក្នុងពេលកំពុងសិក្សា
- ★ រំលស់តែការប្រាក់ប្រចាំខែ ក្នុងពេលកំពុងសិក្សា
- ★ រំលស់ទាំងដើមនិងការប្រាក់ប្រចាំខែ ក្នុងពេលកំពុងសិក្សា

# ឧទាហរណ៍

អ្នកអាចស្វែងរកព័ត៌មានដែលអ្នកត្រូវការ ដើម្បីធ្វើការសំរេចចិត្ត នៅពេលនេះ សេ អឹម កា នឹងផ្តល់ព័ត៌មានលំអិតដល់អ្នកដោយគ្មានការលាក់បាំង ។

## សុធាមិនបង់រំលស់អ្វីទាំងអស់ពេលកំពុងសិក្សា

សុធា ទើបតែបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រឆ្នាំទី១ និង ទី២ ហើយគាត់ចាប់ផ្តើមធ្វើការបាន១ខែ មុននៅក្រុមហ៊ុនឱសថ្យព្យាញមួយ គាត់ទទួលបានប្រាក់ខែ ១៨0ដុល្លារ។ សុធា យកកម្ចីពី សេ អឹម កា ១000 ដុល្លារ ដើម្បីចំណាយលើការសិក្សាឆ្នាំទី៣ និង ទី៤ របស់គាត់បន្តទៀត។ គាត់មិនទាន់មានលទ្ធភាពសងត្រលប់មក សេ អឹម កា វិញ ពេលកំពុងសិក្សានៅឡើយទេ។ នៅពេលគាត់បញ្ចប់ការសិក្សា ទទួលបានបរិញ្ញាប័ត្រហើយ និងមានប្រាក់ខែសមរម្យនោះ គាត់នឹងត្រូវសង ត្រលប់ប្រចាំខែ អោយ សេ អឹម កា វិញនូវសាច់ប្រាក់រំលស់ចំនួន ៣៩.៨៧ដុល្លារ* ក្នុង១ខែ រយៈពេល ៣ ឆ្នាំ ។

## សារុន រំលស់តែការប្រាក់ពេលកំពុងសិក្សា

សារុន ទើបតែបញ្ចប់ថ្នាក់បរិញ្ញាប័ត្ររបស់គាត់ ហើយកំពុងធ្វើការនៅក្រុមហ៊ុនទូរស័ព្ទមួយបាន រយៈពេល ១ឆ្នាំ ហើយគាត់ទទួលបានប្រាក់ខែចំនួន ២00 ដុល្លារ។ គាត់រំពឹងចង់បន្តការសិក្សាថ្នាក់អនុបណ្ឌិត តទៅទៀត។ សេ អឹម កា ផ្តល់កម្ចីជូនគាត់ចំនួន ២000 ដុល្លារ ដើម្បីចំណាយ លើថ្លៃ សិក្សាថ្នាក់អនុបណ្ឌិតរបស់គាត់។ ពេលកំពុងសិក្សា គាត់រំលស់ត្រឹមតែការប្រាក់ប្រចាំខែ សំរាប់ការសិក្សាថ្នាក់ អនុបណ្ឌិតឆ្នាំទី១ មកសេ អឹម កា ចំនួន ១0ដុល្លារ ក្នុង១ខែ តែប៉ុណ្ណោះ ហើយ គាត់នឹង បង់ចំនួន ២0 ដុល្លារ ក្នុង១ខែ សំរាប់ការសិក្សាថ្នាក់អនុបណ្ឌិតឆ្នាំទី២ ។ក្រោយទទួលបាន បរិញ្ញាប័ត្រថ្នាក់អនុបណ្ឌិត សារុន នឹងត្រូវ បង់ រំលស់ទាំងដើមនិង ការប្រាក់ ចំនួន ៦៦.៤៣ដុល្លារ* រៀងរាល់ខែ រយៈពេលរំលោះ ៣ឆ្នាំ។

## ចរិយាមានបំណងចង់សងត្រលប់ភ្លាមៗ

ចរិយាបាន បញ្ចប់ថ្នាក់បរិញ្ញាប័ត្ររបស់នាង ៣ឆ្នាំមុន ហើយនាងកំពុងធ្វើការបាន៣ឆ្នាំមកហើយដែរ នៅ ក្រុមហ៊ុនមួយ ជាមួយនឹងប្រាក់ខែ ៤00ដុល្លារ។ នាងចង់បន្តការសិក្សាថ្នាក់អនុបណ្ឌិត ប៉ុន្តែ នាងមិនទាន់សន្សំបានគ្រប់គ្រាន់ដើម្បីបង់ថ្លៃសិក្សានៅឡើយទេ ។ សេ អឹម កា ផ្តល់កម្ចីអោយ នាង ចំនួន ២៤00 ដុល្លារ សំរាប់ការសិក្សានេះ។ ដោយសារនាងមានលទ្ធភាពបង់រំលស់ ភ្លាមៗបាន នាងបង់ត្រលប់ទាំងដើមនិង ការប្រាក់ មក សេ អឹម កា ចំនួន ៥៣.៣៩ដុល្លារ* រយៈពេល ៥ឆ្នាំ។

*ដោយមិនបូកបញ្ចូលប្រាក់ជានារ៉ាប់រងលើកម្ចី។